ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧ អនក្រ

# សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដឹកនាំ និងជំរុញការអនុវត្តយុទ្ធនាការឃោសនា ផ្សព្វផ្សាយទេសចរណ៍កម្ពុជា " កម្ពុជា: ព្រះរាជាណាចក្រអច្ឆរិយៈ " CAMBODIA-Kingdom of Wonder " និងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ"

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៦/១៥ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- យោងលិខិតលេខ ១៥៦៣ សជណ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការអនុញ្ញាតជាគោលការណ៍បង្កើតគណៈកម្មការអន្តរក្រសួងដើម្បីដឹកនាំ និងអនុវត្តយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍កម្ពុជា
- យោងតាមសំណើសុំរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

### ស ម្រេ ច

**ប្រការ១:** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដឹកនាំ និងជំរុញការអនុវត្តយុទ្ធនាការឃោសនាផ្សព្វផ្សាយទេសចរណ៍កម្ពុជា "**កម្ពុជា: ព្រះរាជាណាចក្រអច្ឆរិយៈ**" និងចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ**" រួមមានសមាសភាពដូចតទៅ:

១- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រធានកិត្តិយស

២- ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ប្រធាន

៣- ឯកឧត្តមនាយឧត្តមសេនីយ៍ **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

Downloaded from http://www.khmerlaws.com

៤- ប្រធានគណៈកម្មការគ្រប់គ្រងអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្តទាំង២៤ អនុប្រធាន
៥- ឯកឧត្តម **សំ ព្រហ្មនា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន
៦- ឯកឧត្តម **រស់ រ៉េន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន
៧- ឯកឧត្តម **សូ ម៉ារ៉ា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធានប្រចាំការ
៨- ឯកឧត្តម **គោស៊ុំ សារឿត** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន
៩- ឯកឧត្តម **ម៉ៅ អាយុទ្ធ** រដ្ឋលេខាធិការក្រសួងព័ត៌មាន អនុប្រធាន
១០- ឯកឧត្តម **ថៃ នរៈសត្យា** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អនុប្រធាន
១១- ឯកឧត្តម **ស៊ឹម វណ្ណា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន
១២- ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ អនុប្រធាន
១៣- ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក ✓
១៤- ឯកឧត្តម **ម៉ៅ ថូរ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក
១៥- ឯកឧត្តម **អេង ហួត** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
១៦- ឯកឧត្តម **តូច ចាន់កុសល** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
១៧- ឯកឧត្តម **អ៊ិន ចន្ថា** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
១៨- ឯកឧត្តម **ពិត ចំណាន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
១៩- ឯកឧត្តម **យិន គឹមស៊ាន** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
២០- ឯកឧត្តម **លឹម សូគុន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
២១- ឯកឧត្តម **ពេជ សោភ័ន** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
២២- លោកជំទាវ **ឃឹម ចំរើន** រដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិក
២៣- ឯកឧត្តម **តោ សឿត** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
២៤- ឯកឧត្តម **កុយ គួង** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
២៥- ឯកឧត្តម **ទី តាយី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
២៦- ឯកឧត្តមឧត្តមសេនីយ៍ឯក **សូ ផន** អគ្គស្នងការរងនគរបាលជាតិ សមាជិក
២៧- ឯកឧត្តមឧត្តមសេនីយ៍ឯក **អ៊ុក គឹមលេខ** អគ្គស្នងការរងនគរបាលជាតិ សមាជិក
២៨- ឯកឧត្តម **លេង វី** អគ្គនាយករដ្ឋបាល នៃក្រសួងមហាផ្ទៃ សមាជិក
២៩- ឯកឧត្តម **ប៊ុន ណារិទ្ធ** អគ្គនាយកអាជ្ញាធរអប្សរា សមាជិក
៣០- លោក **ស ថេង** អគ្គនាយករងគយ និងរដ្ឋាករកម្ពុជា សមាជិក

**ប្រការ២:** គណៈកម្មការអន្តរក្រសួងដើម្បីដឹកនាំ និងជំរុញការអនុវត្តយុទ្ធនាការឃោសនាផ្សព្វផ្សាយទេសចរណ៍កម្ពុជា "**កម្ពុជា: ព្រះរាជាណាចក្រអច្ឆរិយៈ**" និងចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ**" មានមុខងារ និងភារកិច្ចដូចតទៅ:

Downloaded from http://www.khmerlaws.com

- រៀបចំផែនការ និងយុទ្ធសាស្ត្រនានាដើម្បីជម្រុញយុទ្ធនាការនេះឱ្យបានជោគជ័យ និងទទួលលទ្ធផលល្អប្រសើរ ។
- ជំរុញដំណើរការអនុវត្តន៍យុទ្ធនាការផ្សព្វផ្សាយទេសចរណ៍កម្ពុជា "**កម្ពុជា: ព្រះរាជាណាចក្រអច្ឆរិយៈ**" ឱ្យបានទូលំទូលាយ ស៊ីជំរៅនៅក្នុងប្រទេស និងក្រៅប្រទេស តាមគ្រប់រូបភាព និងគ្រប់មធ្យោបាយ ។
- ចាត់តាំង និងបំផុសចលនាប្រជាជន និងមហាជនចូលរួមឱ្យបានច្រើនគ្នាក្នុងចលនាប្រឡងប្រណាំង **ទីក្រុងស្អាត រមណីយដ្ឋានស្អាត និងសេវាល្អ** ដើម្បីបង្កើតឱ្យបាននូវផលិតផលទេសចរណ៍ថ្មីៗប្រកបដោយសុវត្ថិភាព គុណភាព និងអនាម័យល្អជាទីទាក់ទាញ និងពេញចិត្តដល់ភ្ញៀវទេសចរ ។
- ធ្វើការសិក្សា វិភាគ និងវាយតម្លៃអំពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកលលោក និងបញ្ហាផ្សេងៗទៀតដែលជះឥទ្ធិពលមកលើវិស័យទេសចរណ៍កម្ពុជា ដើម្បីលើកឡើងនូវយុទ្ធសាស្ត្រ និងដាក់ចេញនូវគោលនយោបាយគន្លឹះនានាឱ្យបានសមស្របតាមដំណាក់កាលនីមួយៗជូនប្រមុខរដ្ឋាភិបាលពិនិត្យ និងសម្រេច ។
- ពង្រឹង និងរក្សាការពារសន្តិសុខ សុវត្ថិភាពជូនភ្ញៀវទេសចរ និងរក្សាសណ្តាប់ធ្នាប់ អនាម័យសាធារណៈនៅតាមគោលដៅទេសចរណ៍ និងរមណីយដ្ឋានទេសចរណ៍ ។
- ជំរុញការអនុវត្តច្បាប់ស្តីពីទេសចរណ៍ឱ្យបានល្អប្រសើរ សំដៅធានាការផ្តល់សេវាសាធារណៈជូនផ្នែកឯកជនក្នុងឧស្សាហកម្មទេសចរណ៍ឱ្យបានងាយស្រួល និងធានាការគ្រប់គ្រងសេវា និងផលិតផលទេសចរណ៍ប្រកបដោយគុណភាព ។
- ខិតខំសហការដើម្បីធានាដល់ការអភិវឌ្ឍន៍ទេសចរណ៍កម្ពុជាមួយប្រកបដោយគុណភាព ប្រសិទ្ធភាព និរន្តរភាព និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តន៍ការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ៣:** គណៈកម្មការនេះ មានអនុគណៈកម្មការចំនួន ៣ រួមមាន:

**៣.១.អនុគណៈកម្មការសិក្សាទីផ្សារ ផ្សព្វផ្សាយ និងព័ត៌មាន**

| | | |
|---|---|---|
| ១- ឯកឧត្តម **សូ ម៉ារ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម **ម៉ៅ អាយុទ្ធ** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៣- ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៤- ឯកឧត្តម **ម៉ៅ ថូរ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៥- ឯកឧត្តម **ទៃ នរៈសត្យា** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៦- ឯកឧត្តម **ពិត ចំណាន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៧- ឯកឧត្តម **ឆាក់ សុខុម** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធានប្រចាំការ |
| ៨- ឯកឧត្តម **ឆាន់ ចន្ទ្រា** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៩- ឯកឧត្តម **កុយ គួង** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១០- ឯកឧត្តម **ទី តាឃី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១- ឯកឧត្តម **ខិត នារារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |

Downloaded from http://www.khmerlaws.com

១២- ឯកឧត្តម **ភីម គុណវឌ្ឍន៍** អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា សមាជិក

១៣-ឯកឧត្តម **ឆិត ចន្ថា** អគ្គនាយកទេសចរណ៍ នៃក្រសួងទេសចរណ៍ សមាជិក

១៤- ឯកឧត្តម **ម៉ី ម៉ារ៉ាឌី** អគ្គនាយករងអាជ្ញាធរអប្សរា សមាជិក

១៥- លោក **ស ថេង** អគ្គនាយករងគយ និងរដ្ឋាករកម្ពុជា សមាជិក

១៦- លោក **ឆ្នុំង ឡើន** អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ សមាជិក

១៧- លោក **សុខ សុខហាក់** ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ សមាជិក

១៨- លោក **ជុក សុខុម** ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍ សមាជិក

១៩- លោក **សូ ទិសុទ្ធី** ប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ នៃក្រសួងទេសចរណ៍ សមាជិក

២០- លោក **គង់ សុភារក្ស** ប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍ នៃក្រសួងទេសចរណ៍ សមាជិក

**អនុគណៈកម្មការនេះមានភារកិច្ចៈ**

សហការជាមួយផ្នែកឯកជនៈ

- ដើម្បីរៀបចំផែនការ និងយុទ្ធសាស្ត្រនៅតាមទីផ្សារទេសចរណ៍សំខាន់ៗដើម្បី ជំរុញយុទ្ធនាការនេះឱ្យបាន ជោគជ័យតាមគ្រប់រូបភាព និងគ្រប់មធ្យោបាយ ។
- ធ្វើការសិក្សា វិភាគ និងវាយតម្លៃអំពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកលលោក និងបញ្ហាផ្សេងៗទៀត ដែលជះឥទ្ធិពលមកលើវិស័យទេសចរណ៍កម្ពុជា ។
- រៀបចំខ្លឹមសារ ផែនការ និងកម្មវិធីស្តីពីយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍កម្ពុជា "**កម្ពុជាៈ ព្រះរាជាណាចក្រ អច្ឆរិយៈ**" និងលើកឡើងនូវគោលនយោបាយគន្លឹះសំខាន់ៗដើម្បីជំរុញការអភិវឌ្ឍទេសចរណ៍ ។

**៣.២. អនុគណៈកម្មការអប់រំការយល់ដឹងជាសាធារណៈ និងពង្រឹងគុណភាពផលិតផល សេវាកម្មទេសចរណ៍ និងការ ជំរុញចលនាប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាត និងសេវាល្អ**

១- ឯកឧត្តម **សំ ព្រហ្មនា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ ប្រធាន

២- ឯកឧត្តម **រស់ រ៉េន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន

៣- ឯកឧត្តម **គោស៊ុំ សារឿត** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន

៤- ឯកឧត្តម **ជុំ អឿក** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន

៥- ឯកឧត្តម **តូច ចាន់កុសល** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន អនុប្រធាន

៦- ឯកឧត្តម **អេង ហួត** រដ្ឋលេខាធិការក្រសួងសុខាភិបាល អនុប្រធាន

៧- ឯកឧត្តម **ម៉ៅ ថូរ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

៨- ឯកឧត្តម **សោ សឿត** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៩- ឯកឧត្តម **ពេជ សោភ័ន** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១០- ឯកឧត្តម **យិន គីមស៊ាន** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

១១- ឯកឧត្តម **ថៃ នរៈសត្យា** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

Downloaded from http://www.khmerlaws.com

| | | |
|---|---|---|
| ១២- ឯកឧត្តម **លឹម សុគុន** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣- ឯកឧត្តម **ដោក ណារិន** | រដ្ឋលេខាធិការក្រសួងធម្មការ និងកិច្ចការសាសនា | សមាជិក |
| ១៤- លោកជំទាវ **ឃឹម ចំរើន** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ១៥- ឯកឧត្តម **សៀង គឹមហាន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៦- ឯកឧត្តម **លី ថ៊ុនធៀន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៧- ឯកឧត្តម **គីមអ៊ុចំនួនសារមិត្រ** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៨- ឯកឧត្តម **ស្តើង សុខុម** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៩- ឯកឧត្តម **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២០- ឯកឧត្តម **លេង វី** | អគ្គនាយករដ្ឋបាល នៃក្រសួងមហាផ្ទៃ | សមាជិក |
| ២១- ឯកឧត្តម **និត ចន្ថា** | អគ្គនាយកទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិកប្រចាំការ |
| ២២- ឯកឧត្តម **ខាំ មុរ៉ា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៣-ឯកឧត្តម **ម៉ី ម៉ារ៉ាឌី** | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ២៤- លោក **កើត ពុទ្ធចរី** | អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៥- លោក **អ៊ុំ ឃឹម** | អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៦- លោក **ខួង ទីរៈ** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៧- លោក **ប្រាក់ ចន្ទ័នារា** | ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៨- លោក **កែវ ភួង** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៩- លោក **ខាំ ចំនួនដារី** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៣០- លោក **ម៉ៅ សុផាត** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ | លេខាធិការ |
| ៣១- លោកស្រី **ដោក ស៊ីណារ៉ា** | មន្ត្រីនាយកដ្ឋានឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |

**អនុគណៈកម្មការនេះមានភារកិច្ចៈ**

- សហការជាមួយផ្នែកឯកជន រៀបចំកម្មវិធីបណ្តុះបណ្តាល និងបំពាក់បំប៉នផ្នែកជំនាញទៅតាមគោលដៅទេសចរណ៍នានាតាមការចាំបាច់
- រៀបចំផែនការ កម្មវិធីនៃយុទ្ធនាការអប់រំការយល់ដឹងសាធារណៈ និងចាត់តាំង និងបំផុសចលនាប្រលងប្រណាំង **ទីក្រុងស្អាត រមណីយដ្ឋានស្អាត និងសេវាល្អ**
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សា និងលើកឡើងនូវគម្រោងផែនការជំរុញការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗបំរើឱ្យការអភិវឌ្ឍន៍ទេសចរណ៍។
- ធ្វើការពង្រឹងគុណភាពផលិតផលទេសចរណ៍ និងសេវាកម្មទេសចរណ៍ឱ្យមានលក្ខណៈស្តង់ដារ ដើម្បីឱ្យសមស្របទៅនឹងតំរូវការ និងកំណើនទេសចរបច្ចុប្បន្ន
- ជំរុញការពង្រឹងគុណភាពអនាម័យម្ហូបអាហារ
- ជំរុញការអភិវឌ្ឍន៍ និងគ្រប់គ្រងរមណីយដ្ឋានទេសចរណ៍

Downloaded from http://www.khmerlaws.com

- ពង្រឹងការគ្រប់គ្រងសេវាលក់ដូរ និងគុណភាពវត្ថុអនុស្សាវរីយ៍
- ពង្រឹងគុណភាពសេវាមគ្គុទេសក៍ទេសចរណ៍
- សហគមទេសចរណ៍មូលដ្ឋាន
- លុបបំបាត់ចោលការយកកំរៃជើងសារមិនសមហេតុសមផល
- ពិនិត្យ លើកសរសើរ និងជូនរង្វាន់ដល់អាជ្ញាធរ ស្ថាប័ន អង្គភាព ក្រុមហ៊ុន និងបុគ្គលដែលមានស្នាដៃល្អ ក្នុងការលើកកំពស់គុណភាព ទីក្រុង រមណីយដ្ឋាន សេវាកម្មរបស់ខ្លួន ។
- ចលនាជាំផ្ទះដំណាំកសិកម្មដែលបំរើដល់ឧស្សាហកម្មទេសចរណ៍ ។

**៣.៣. អនុគណៈកម្មការសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ អនាម័យសាធារណៈ**

| | | |
|---|---|---|
| ១- ឯកឧត្តមនាយឧត្តមសេនីយ៍ **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម **គោស៊ុំ សារឿត** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- ឯកឧត្តមឧត្តមសេនីយ៍ឯក **សូ ផន** | អគ្គស្នងការរងនគរបាលជាតិ | អនុប្រធាន |
| ៥- ឯកឧត្តមឧត្តមសេនីយ៍ឯក **អ៊ុក គីមលេខ** | អគ្គស្នងការរងនគរបាលជាតិ | អនុប្រធាន |
| ៦- ឯកឧត្តម **ជុំ អឿត** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧- ឯកឧត្តម **តោ សឿត** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៨- ឯកឧត្តម **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក និងជាលេខាធិការ |
| ៩- ឧត្តមសេនីយឯក **ទាំង ណាយ** | ប្រធាននាយកដ្ឋាននគរបាលកណ្តាលយុត្តិធម៌ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១០- ឧត្តមសេនីយ៍ទោ **ញាណ វិបុល** | ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១១- ឧត្តមសេនីយ៍ទោ **គូ ខន** | ប្រធាននាយកដ្ឋាននគរបាលសណ្តាប់ធ្នាប់ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១២- លោក **រស់ សំអុំ** | អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៣- លោក **អ៊ុំ ឃីម** | អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៤- លោក **សៅ សារឿន** | អធិការនៃក្រសួងទេសចរណ៍ | សមាជិក |
| ១៥- ឧត្តមសេនីយ៍ត្រី **ពិន ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ | សមាជិក |

**អនុគណៈកម្មការនេះមានភារកិច្ចៈ**

- រក្សាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ជូនភ្ញៀវទេសចរជាតិ-អន្តរជាតិ ។
- ទំនាក់ទំនង និងសហការជិតស្និទ្ធជាមួយគណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត ។
- រៀបចំក្បួននាំមុខ និងការការពារសន្តិសុខ សុវត្ថិភាពជូនគណៈប្រតិភូ និងក្រុមទេសចរសំខាន់ៗដែលមកទស្សនាកម្ពុជា ។

Downloaded from http://www.khmerlaws.com

**ប្រការ៤:** គណៈកម្មការនេះ មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅទីស្តីការក្រសួងទេសចរណ៍ មានសមាសភាព ដូចខាងក្រោម:

១-ឯកឧត្តម **ធិត ចន្ថា** អគ្គនាយកទេសចរណ៍ នៃក្រសួងទេសចរណ៍ ប្រធាន
២-ឯកឧត្តម **ជា បូរ៉ា** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ អនុប្រធាន
៣-ឯកឧត្តម **អ៊ុក ស៊ីផាន** ទីប្រឹក្សាអមក្រសួងទេសចរណ៍ អនុប្រធាន
៤-ឯកឧត្តម **ម៉ី ម៉ារ៉ាឌី** អគ្គនាយករងអាជ្ញាធរអប្សរា សមាជិក
៥-លោក **អ៊ុំ ឃឹម** អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ អនុប្រធាន
៦-លោក **ផ្លុង ធឿន** អគ្គនាយករងទេសចរណ៍នៃក្រសួងទេសចរណ៍ អនុប្រធាន
៧-លោក **ឌួង វីរៈ** អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ អនុប្រធាន
៨-លោក **គង់ សូលីដា** អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី សមាជិក
៩-ឧត្តមសេនីយឯក **វ៉ាន់ ណាយ** ប្រធាននាយកដ្ឋាននគរបាលកណ្តាលយុត្តិធម៌ នៃក្រសួងមហាផ្ទៃ សមាជិក
១០-ឧត្តមសេនីយ៍ទោ **ញាណ វិមុល** ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ នៃក្រសួងមហាផ្ទៃ សមាជិក
១១-លោក **សៅ សារឿន** អធិការនៃក្រសួងទេសចរណ៍ សមាជិក
១២-លោក **សូ វិសុទ្ធិ** ប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយនៃក្រសួងទេសចរណ៍ សមាជិក
១៣-លោក **សុខ តុងហាប់** ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ សមាជិក
១៤-លោក **អ៊ុក សុខា** ប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ សមាជិក
១៥-លោក **ទ្រាក់ ច័ន្ទតារា** ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ សមាជិក
១៦-លោក **សុខ សុគុណា** ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ នៃក្រសួងទេសចរណ៍ សមាជិក
១៧-លោក **កែវ ត្នួន** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ នៃក្រសួងទេសចរណ៍ សមាជិក
១៨-ឧត្តមសេនីយ៍ត្រី **ពិន ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ សមាជិក
១៩-លោក **ត្នួន វណ្ណៈ** អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ សមាជិក
២០-លោក **កែវ វាសនា** នាយកការិយាល័យសរុប នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ លេខាធិការ

**លេខាធិការដ្ឋាននេះមានភារកិច្ច:**

- បូកសរុបលទ្ធផលការងារអនុវត្តរបស់អនុគណៈកម្មការនិមួយៗ។
- រៀបចំផែនការ កម្មវិធីប្រជុំរបស់គណៈកម្មការឱ្យបានទៀតទាត់។
- សម្រួលដោះស្រាយមធ្យោបាយ សម្ភារៈ ថវិកា ដើម្បីបំរើការងារ និងសកម្មភាពរបស់គណៈកម្មការ។
- បូកសរុបលទ្ធផលការងារអនុវត្តរបស់គណៈកម្មការ និងរាយការណ៍ជូនរាជរដ្ឋាភិបាល។

**ប្រការ៥:** -គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍ ក្នុងការជំរុញយុទ្ធនាការខាងលើឱ្យទទួលបានជោគជ័យ។

-សមាជិកនៃគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

Downloaded from http://www.khmerlaws.com

-អនុគណៈកម្មការនីមួយៗមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួនបន្ថែមក្នុងករណីមានការចាំបាច់ ។

**ប្រការ៦:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាល រាជធានី ខេត្ត ក្រុង ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ប្រការ ៣ និងប្រការ ៤ ខាងលើ ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចប្រការ៧*
*-ឯកសារ-កាលប្បវត្តិ*

Downloaded from http://www.khmerlaws.com